**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ១៨៧៥ ព.ណ.ន.សហការ

ថ្ងៃសុក្រ ៤កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០២៦

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាពាណិជ្ជករ និងសាធារណជនទូទៅឱ្យបានជ្រាបថា លេខាធិការដ្ឋាន China-Eurasia នឹងរៀបចំពិព័រណ៍ «The 9th China-Eurasia Expo» ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៥-២៩ ខែមិថុនា ឆ្នាំ២០២៦ នៅខេត្តស៊ីនជាំង សាធារណរដ្ឋប្រជាមានិតចិន។ ព្រឹត្តិការណ៍នេះនឹងបង្ហាញពីសមិទ្ធផល ផលិតផល បច្ចេកវិទ្យា និងសេវាកម្មថ្មីៗក្នុងការអភិវឌ្ឍខ្សែច្រវាក់ឧស្សាហកម្មពីតំបន់អាស៊ី-អឺរ៉ុប។ ពិព័រណ៍នេះក៏នឹងលើកកម្ពស់ការវិនិយោគ និងពាណិជ្ជកម្ម ព្រមទាំងមានរៀបចំសកម្មភាពគាំទ្រសំខាន់ៗមួយចំនួនក្នុងអំឡុងពេលពិព័រណ៍ ដើម្បីសម្រួលដល់ការផ្គូផ្គងរវាងខ្សែច្រវាក់ឧស្សាហកម្មក្នុងស្រុក និងអន្តរជាតិ និងបង្កើតកិច្ចសហប្រតិបត្តិការបន្ថែមទៀតរវាងប្រទេសចិន និងបណ្តាប្រទេសអាស៊ី-អឺរ៉ុប។ ព្រឹត្តិការណ៍ពិព័រណ៍នេះ នឹងផ្តល់ឱកាសជូនធុរជនកម្ពុជាក្នុងការស្វែងរកដៃគូធុរកិច្ចចិន និងបណ្តាប្រទេសអាស៊ី-អឺរ៉ុបផងដែរ។

ក្រសួងពាណិជ្ជកម្ម ក្នុងនាមអ្នកសម្របសម្រួល សូមអញ្ជើញលោក-លោកស្រី ដែលជាពាណិជ្ជករ និងសាធារណជន ដែលមានចំណាប់អារម្មណ៍ចង់ចូលរួមព្រឹត្តិការណ៍ខាងលើ សូមទាក់ទងឈ្មោះ Kelly Nie តាមរយៈអ៊ីម៉ែល caeexpo@vip.163.com ឬទូរស័ព្ទលេខ +86 15610167370។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកមន្ត្រីសម្របសម្រួល តាមរយៈទូរស័ព្ទលេខ +៨៥៥ ៨៦ ៣៣៣ ៩៣៣ / +៨៥៥ ៧៧ ៣៦១ ៨៣៦ ឬអ៊ីម៉ែល sorn.pitou@moc.gov.kh / oun.veasna@moc.gov.kh ឬតាមរយៈប្រព័ន្ធទូរស័ព្ទសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ១២៦៦៕

**សូមអរគុណ!**

សម្រាប់ចុះឈ្មោះ:

GO.gov.KH

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61,Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469